00495853

D337/2

# មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០

**ផ្ញើពី:** មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

**គោរពជូន:** ការិយាល័យសហចៅក្រមស៊ើបអង្កេត

**យោង:** ពេលផុតកំណត់សម្រាប់ការដាក់ព័ត៌មានបន្ថែម

ជូនលោកចៅក្រម យូ ប៊ុនឡេង និងចៅក្រម Marcel LEMONDE,

នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ លោកចៅក្រមបានកំណត់ពេលផុតកំណត់សម្រាប់ការដាក់ព័ត៌មានបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃការស៊ើបអង្កេតសម្រាប់សំណុំរឿង០០២ ដែលត្រូវធ្វើឡើងនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១០។

នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០នេះ លោកចៅក្រម LEMONDE បានប្រកាសជាសាធារណៈក្នុងអំឡុងពេលអង្គប្រជុំនៃតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថា អង្គភាពគាំពារជនរងគ្រោះត្រូវបានផ្តល់ជូនពេលវេលាមួយខែបន្ថែមទៀត ក្នុងការដាក់ទម្រង់បែបបទព័ត៌មានជនរងគ្រោះទៅការិយាល័យសហចៅក្រមស៊ើបអង្កេត។

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួលសិទ្ធិចូលមើលទម្រង់បែបបទព័ត៌មានជនរងគ្រោះ និងរបាយការណ៍ជាភាសាអង់គ្លេសនៃអង្គភាពគាំពារជនរងគ្រោះឡើយ ប្រសិនបើឯកសារទាំងនេះមិនត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងទេនោះ។ អង្គភាពគាំពារជនរងគ្រោះប្រហែលជានឹងបញ្ជូនទម្រង់បែបបទ និងរបាយការណ៍ទាំងអស់នៅចុងពេលផុតកំណត់ដែលទើបបានពន្យាតថ្មីនេះ គឺនៅចុងខែមេសា ប៉ុន្តែមិនមែនមានន័យថា ទម្រង់បែបបទ និងរបាយការណ៍ទាំងនេះនឹងមានភ្លាមៗនៅក្នុងសំណុំរឿងឡើយ។

ដោយថា យើងខ្ញុំពឹងផ្អែកទៅលើព័ត៌មានទាំងនេះ ក្នុងការវាយតម្លៃ ប្រសិនបើតម្រូវឱ្យមានព័ត៌មានបន្ថែមទៀត យើងខ្ញុំសូមស្នើដោយគោរពឱ្យមានការពន្យាតពេលផុតកំណត់ ១(មួយខែ)បន្ថែមទៀត គឺរហូតដល់ត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០។

ដោយក្តីគោរព

លោកស្រីស៊ីន សុវន, លោក ហុង គឹមសួន, លោកស្រី ជេត វណ្ណលី, លោក គឹម ម៉េងឃី, កញ្ញា ម៉ុច សុវណ្ណារី, Ms. Martine JACQUIN, Mr. Philippe CANONNE, Ms. Annie DELAHAIE, Ms. Elizabeth RABESANDRATANA, Ms. Fabienne TRUSSES-NAPROUS, Ms. Laure DESFORGES, Ms. Christine MARTINEAU, Ms. Isabelle DURAND, Ms. Françoise GAUTRY, Ms. Silke STUDZINSKY

ឯកសារថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 12 / 04 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 08 / 04 / 2010
ម៉ោង (Time/Heure): 9:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé